HWDSB

ញាតិមិត្តទាំងឡាយជាទីស្នេហា

នៅឯសិក្សាធិការដ្ឋានតំបន់ Hamilton-Wentworth (HWDSB)
កិច្ចការចំបងមួយក្នុងចំណោមអាទិភាពធំបំផុតរបស់យើងគឺធានាឱ្យសិស្សទាំងអស់ទៅដល់សាលារៀនដោយសុវត្ថិភាពជារៀងរាល់ថ្ងៃ។

ដើម្បីពង្រឹងនីតិវិធីរបស់យើងចំពោះអវត្តមាន យើងនឹងប្រើប្រាស់ **SafeArrival** គឺប្រព័ន្ធរបាយការណ៍អវត្តមាននៃសិស្សដែលនឹងអនុញ្ញាតិឱ្យលោកអ្នករាយការណ៍អំពីអវត្តមានយ៉ាងងាយស្រួល។ វាក៏នឹងអនុញ្ញាតិឱ្យបុគ្គលិកសាលាឆ្លើយតបយ៉ាងឆាប់រហ័សនិងយ៉ាងហ្មត់ចត់ចំពោះអវត្តមានដែលមិនដឹងពីមូលហេតុ។
គោលដៅរបស់យើងគឺបន្តពន្យល់អំពីអវត្តមានទាំងអស់ហើយរាប់សិស្សទាំងអស់ជារៀងរាល់ថ្ងៃឱ្យដឹងថាពួកគេមានសុវត្ថិភាព។

ដោយប្រើ SafeArrival ក្រុមគ្រួសាររាយការណ៍អំពីអវត្តមានរបស់កុមារតាមវិធីមួយក្នុងចំណោមវិធីទាំងបីយ៉ាង៖

1. សូមប្រើគេហទំព័រនៃ SafeArrival ដោយវាយអក្សរ go.schoolmessenger.ca។ លោកអ្នកដែលប្រើគេហទំព័រនៅលើកទីមួយ សូមចុច **Sign Up** ដើម្បីបង្កើតគណនីរបស់លោកអ្នក។ បន្ទាប់មក សូមជ្រើស **Attendance** រួច **Report an Absence**.
2. ដោយប្រើឧបករណ៍ចល័តរបស់លោកអ្នក សូមទាញយក (Download) និងតំឡើងកម្មវិធី SchoolMessenger ពី Apple App Store ឬ Google Play Store (ឬពីសម្ព័ន្ធនានានៅ go.schoolmessenger.ca) ។ លោកអ្នកដែលប្រើកម្មវិធីនៅលើកទីមួយ សូមចុច **Sign Up** ដើម្បីបង្កើតគណនីរបស់លោកអ្នក។ បន្ទាប់មក សូមជ្រើស **Attendance** រួច **Report an Absence**.
3. សូមទូរស័ព្ទទៅលេខឥតគិតថ្លៃ 844-506-4350 ដើម្បីរាយការណ៍អំពីអវត្តមានដោយប្រើប្រព័ន្ធទូរស័ព្ទ ស្វ័យប្រវត្តិ។

ជម្រើសទាំងនេះអាចប្រើបាន 24 ម៉ោងរៀងរាល់ថ្ងៃ, 7 ថ្ងៃក្នុងមួយសប្តាហ៍។ លោកអ្នកអាចរាយការណ៍អំពីអវត្តមានពេលណាក៏បាន។

លើសពីនេះទៀត យើងនឹងប្រើប្រព័ន្ធជូនដំណឹងដោយស្វ័យប្រវត្តិឈ្មោះ **SchoolMessenger Communicate** ដើម្បីទាក់ទងឪពុកម្តាយរបស់កូនដែលបាត់មុខនៅពេលអវត្តមានមិនត្រូវបានរាយការណ៍ជាមុន។ ប្រព័ន្ធជូនដំណឹងដោយស្វ័យប្រវត្តិនឹងព្យាយាមទាក់ទងឪពុកម្តាយជាច្រើនដងរហូតទាល់តែឪពុកម្តាយបញ្ជាក់ប្រាប់និងពន្យល់ពីអវត្តមាន។ ប្រសិនបើប្រព័ន្ធនេះមិនអាចទាក់ទងនឹងបុគ្គលដូចបានកំណត់នោះទេ បុគ្គលិកការិយាល័យនឹងតាមដាន។

ប្រសិនបើលោកអ្នករាយការណ៍អំពីអវត្តមានរបស់កូនលោកអ្នកជាមុនដោយប្រើលេខឥតគិតថ្លៃនៃ **SafeArrival** ឬប្រើគេហទំព័រ ឬកម្មវិធីចល័ត លោកអ្នកនឹងមិនទទួលការជូនដំណឹងទាំងនេះទេ។

**ចាប់ពីថ្ងៃទី 23 ខែមេសាឆ្នាំ 2019** សូមរាយការណ៍អំពីអវត្តមានជាមុនដោយប្រើ **SafeArrival** ជំនួសការផ្ញើកំណត់ត្រា ឬទូរស័ព្ទ ឬអ៊ីម៉ែលទៅសាលា។ នៅថ្ងៃនោះ បុគ្គលិកនឹងចាប់ផ្តើមប្រើប្រាស់ការជូនដំណឹងតាម **SafeArrival** ដើម្បីឱ្យលោកអ្នកដឹងប្រសិនបើសិស្សបាត់មុខ (នៅពេលដែលលោកអ្នកមិនបានរាយការណ៍ពីអវត្តមានជាមុន)។

ប្រសិនបើលោកអ្នកមានសំណួរសូមជួបនិយាយជាមួយការិយាល័យ ឬនាយកសាលារបស់លោកអ្នក។ សូមរកធនធាននានាបន្ថែមអំពី SafeArrival នៅ bit.ly/safearrivalHWDSB និងនៅលើគេហទំព័ររបស់សាលា។

សូមអរគុណចំពោះអំណត់និងកិច្ចសហប្រតិបត្តិការរបស់លោកអ្នកក្នុងខណៈដែលយើងអនុវត្តប្រព័ន្ធថ្មីនេះ។